# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសពត៌មាន</u>

# ឯកអគ្គរាជទូតអញ្ជើញទស្សនកិច្ចទៅកាន់ ខេត្តសៀមរាប

ឯកអគ្គរាជទូតអូស្ត្រាលី លោកជំទាវ **អេនជេលឡា ខកខឺរ៉េន** នឹងអញ្ជើញធ្វើទស្សនកិច្ចទៅកាន់ខេត្តសៀមរាប នៅថ្ងៃទី១-៣ ខែសីហា ដើម្បីពិនិត្យប្រតិបត្តិការនៃកម្មវិធីជំនួយអូស្ត្រាលីនៅទីនោះ។

លោកជំទាវឯកអគ្គរាជទូតខកខឺរ៉េន នឹងអញ្ជើញទៅពិនិត្យផ្លូវចំនួនពីរខ្សែរ ដែលត្រូវបានស្តារនិងជួសជុលក្រោមកម្មវិធីជំនួយអូស្ត្រាលី ហៅថាគម្រោងស្តារឡើងវិញបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធខូចខាតដោយទឹកជំនន់ និងគម្រោងស្តារផ្លូវជនបទជំហានពីរ។

លោកជំទាវនឹងជួបប្រជុំជាមួយទូតយុវជនសម្រាប់ការងារសុវត្ថិភាពផ្លូវថ្នល់ ដែលជាផ្នែកមួយនៃកម្មវិធីឧបត្ថម្ភដោយអូស្ត្រាលីដើម្បីពង្រឹងនូវសុវត្ថិភាពផ្លូវថ្នល់ក្នុងខេត្តសៀមរាប។

លោកជំទាវក៏នឹងជួបជាមួយឯកឧត្តម **ឃឹម ប៊ុនសុខ** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងកម្មវិធីជំនួយទាំងនេះ ក៏ដូចជាការគាំទ្ររបស់អូស្ត្រាលីនៅក្នុងខេត្តទាំងមូល ក្រោមកិច្ចសហប្រតិបត្តិការជំនួយអភិវឌ្ឍន៍អូស្ត្រាលី។

លោកជំទាវខកខឺរ៉េន ក៏នឹងចូលរួមជាវាគ្មិនដើម្បីឆ្លើយតបនឹងសំណួរស្តីអំពីទំនាក់ទំនងរបស់អូស្ត្រាលីនៅក្នុងខេត្តសៀមរាប ក្នុងកម្មវិធីសន្ទនាមតិតាមរយៈវិទ្យុនគរភ្នំ FM ១០៣ នៅថ្ងៃទី១ ខែសីហា នាពេលព្រឹកវេលាម៉ោង ១១០០ ដល់ ១២០០។

លោកជំទាវបានមានប្រសាសន៍ថា «អូស្ត្រាលីមានមោទនភាពក្នុងការគាំទ្រដល់កម្មវិធីនានាដើម្បីធ្វើឲ្យប្រសើរឡើងដល់ជីវភាពប្រជាជននៅខេត្តសៀមរាប»។

លោកជំទាវបានបន្តថា «យើងកំពុងសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានាដើម្បីលើកកម្ពស់ឱកាសសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍សហគមន៍នៅខេត្តសៀមរាបឲ្យកាន់តែរីកចម្រើនប្រកបដោយសុខសុវត្ថិភាព»។

នៅក្នុងខេត្តសៀមរាប ឯកអគ្គរាជទូតនឹងអញ្ជើញថ្លែងសុន្ទរកថានៅក្នុងសន្និសីទសន្តិភាពអាស៊ី ដែលរៀបចំដោយមជ្ឈមណ្ឌលសម្រាប់ការសិក្សាអំពីជម្លោះនិងសន្តិភាព។

**ទំនាក់ទំនងពត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au

**ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧**